កិច្ចសន្ទនាភាពជាដៃគូអភិវឌ្ឍន៍កាបូនតិចលើកទីបី នៅអាស៊ីបូព៌ា
ថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៤ នៅទីក្រុង យ៉ូកូហាម៉ា ប្រទេសជប៉ុន

# សុន្ទរកថាក្នុងពិធីបដិសណ្ឋារកិច្ច ដោយ ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្រសួងបរិស្ថាន ព្រះរាជាណាចក្រកម្ពុជា

- សូមគោរព ឯកឧត្តម មីណូរូ គីអូជី រដ្ឋមន្ត្រីកិច្ចការបរទេសប្រទេសជប៉ុន
- ប្រតិភូភ្ញៀវកិត្តិយស
- ឯកឧត្តម លោក លោកស្រីជាទីមេត្រី!

ខ្ញុំសូមអរគុណដែលបានអនុញ្ញាតឲ្យខ្ញុំមានមតិនៅក្នុងឱកាសដ៏ប្រសើរនេះ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមឯកឧត្តម រដ្ឋមន្ត្រី សាយ សំអាល់ សូមអនុញ្ញាតឲ្យខ្ញុំថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះប្រជាជននៃទីក្រុងយ៉ូកូហាមា ដែលបានផ្តល់បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅបំផុត។ ខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលជប៉ុន ដែលបានរៀបចំកិច្ចសន្ទនាភាពជាដៃគូអភិវឌ្ឍន៍កាបូនតិចនៅអាស៊ីបូព៌ាដ៏មានសារៈសំខាន់នេះ ដែលបានឈានដល់ឆ្នាំទីបីទៅហើយ។

ខ្ញុំជឿជាក់ថា យើងទាំងអស់គ្នាមានកង្វល់រួមគ្នា៖ តើយើងធ្វើបែបណាដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមសម្រាប់រយៈពេលវែង ទន្ទឹមនឹងធានាគុណភាពបរិស្ថាន និងសុខភាពនៃផែនដីយើងនេះ? តើយើងធ្វើកិច្ចការនេះបែបណា ដើម្បីផ្តល់ប្រយោជន៍មិនត្រឹមតែសម្រាប់យើងនៅក្នុងពេលនេះប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់មនុស្សជំនាន់ក្រោយៗផងដែរ នៅក្នុងស្ថានភាពមួយដែល ការប្រែប្រួលអាកាសធាតុ បានក្លាយជាកត្តាមិនអាចកាត់ផ្តាច់បានពីរូបមន្តនៃការអភិវឌ្ឍរបស់យើង។ ជាការពិតណាស់ យើងគ្មានចម្លើយងាយស្រួលសម្រាប់កិច្ចការនេះទេ។ ប៉ុន្តែ ខ្ញុំជឿជាក់ថា កិច្ចសន្ទនាបែបនេះ គឺជាវេទិកាសំខាន់មួយសម្រាប់តំបន់យើងនេះ ដើម្បីចែករម្លែកបទពិសោធន៍ និងចំណេះដឹង ដើម្បីផ្លាស់ប្តូរគំនិត និងដើម្បីពិភាក្សាលើបញ្ហានានាដែលជាផលប្រយោជន៍រួម ដើម្បីគាំទ្រដល់ការអភិវឌ្ឍដែលបញ្ចេញកាបូនទាបរបស់យើងរៀងៗខ្លួន។

ខ្ញុំសូមឯកឧត្តម លោក លោកស្រីទាំងអស់ទទួលបានសេចក្តីរីករាយនៅក្នុងពិធីបដិសណ្ឋារកិច្ចនេះ និងមានការសន្ទនាប្រកបដោយជោគជ័យ។ សូមអរគុណ!